មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក(មន្ទីរពេទ្យជប៉ុន)
National Maternal and Child Health Center (NMCHC)



# ការថែទាំម្តាយក្រោយសម្រាលនៅ
# មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

បង្ហាញដោយ លោកស្រីឆ្វាយ ស្វែងជាអាទី៍
រៀបរៀងដោយលោកស្រី ប៉ាន គឹមលៀង

# គោលបំណង

1. ចូលរួមកាត់បន្ថយអត្រាមរណភាពនិងគ្រោះថ្នាក់របស់មាតា
2. បង្កើនទំនុកចិត្តរបស់ស្ត្រីមកលើបុគ្គលិកសុខាភិបាល
3. ចែករំលែកបទពិសោធន៍នៃលទ្ធផលសិក្សា
4. បង្ការនិងព្យាបាលទាន់ពេលវេលានូវផលវិបាកមួយចំនួន

# មាតិកា

1. សេចក្តីផ្តើម
2. ពេលវេលានៃការមកពិនិត្យនិងជំហាននៃការថៃទាំនិមួយៗ
3. លទ្ធផលនៃការសិក្សា
4. សេចក្តីសន្និដ្ឋាន
5. អនុសាសន៍

# ១.សេចក្តីផ្តើម

- ក្រោយសម្រាលគឺគិតចាប់ពីទម្លាក់សុករហូតដល់៤២ថ្ងៃក្រោយសម្រាល។
- ក្រោយសម្រាលភ្លាមៗស្ត្រីត្រូវបានតាមដាន៖ រាល់១៥នាទីម្តងនៅម៉ោងដំបូងក្រោយទម្លាក់សុក រៀងរាល់៣០នាទីម្តងនៅម៉ោងទី២ រៀងរាល់ម៉ោងក្នុងម៉ោងទី៣និងម៉ោងទី៤ និងរៀងរាល់ ៤ម៉ោងក្នុងថ្ងៃដំបូង។
- ការពិនិត្យត្រូវធ្វើរៀងរាល់ថ្ងៃ រហូតដល់ថ្ងៃទី២-៣ក្រោយសម្រាល ឬមុនចាកចេញពីមូលដ្ឋានសុខាភិបាល។ ចាត់ទុកជាការពិនិត្យក្រោយសម្រាល (PNC0)។
- បន្ទាប់ពីចេញពីមូលដ្ឋានសុខាភិបាល ការពិនិត្យក្រោយសម្រាលត្រូវធ្វើក្នុងគោលបំណងផ្តល់នូវកញ្ចប់សេវាថែទាំសុខភាពទាំងមាតានិងទារកតាមពេលវេលាកំណត់ចំនួន៣ដង។

*( ពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មន្ទីរពេទ្យបង្អែក ២០២០)*

# ២.ពេលវេលានៃការមកពិនិត្យនិងជំហាននៃការថែទាំនិមួយៗ

| សេវាកម្ម | ពេលវេលា | កញ្ចប់សេវាដែលត្រូវផ្តល់ |
|---|---|---|
| ពិនិត្យក្រោយសម្រាលលើកទី១ | ថ្ងៃទី៧ក្រោយសម្រាល | • យកសញ្ញាជីវិត (សម្ពាធឈាម ជីពចរ កម្តៅ ចង្វាក់ដង្ហើម)<br>• ពិនិត្យដោះនិង ក្បាលដោះរកមើល(លាសដោះ ប្រេះក្បាលដោះ ក្រហមនៅផ្នែកណាមួយ)<br>• ស្ទាបស្បូន តើមានសភាពមូលនិងរឹងឬទេ? ប្រៀបធៀបកំពូលស្បូនទៅនឹងឆ្អឹងថ្ងាស (Pubis) តើស្បូនរួមតូចសមស្របឬទេ? (ប្រាកដថាគ្មានទឹកនោមក្នុងប្លោកនោម)<br>• មើលយោនីនិងប៉េរីណេដើម្បីរក ការរហែក ហើម ខ្ទុះឬការហូរទឹកនោមដោយឯកឯង |

# ២.ពេលវេលានៃការមកពិនិត្យនិងជំហាននៃការថែទាំនីមួយៗ(ត)

| សេវាកម្ម | ពេលវេលា | កញ្ចប់សេវាដែលត្រូវផ្តល់ |
|---|---|---|
| ពិនិត្យក្រោយសម្រាលលើកទី១ | ថ្ងៃទី៧ក្រោយសម្រាល | • មើលកំណាត់ទ្រាប់គូថឬសំឡីអនាម័យ ដើម្បីមើលការធ្លាក់ឈាមនិងកករឈ្លោក(ក្លិន និងបរិមាណ)<br>• បញ្ជូនម្តាយទៅចុះឈ្មោះនៅសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART site)ដើម្បីទទួលបានឱសថប្រឆាំងមេរោគអេដស៍ (ក្នុងករណីគាត់មិនទាន់បានទទួលការព្យាបាលសោះ)<br>• ការបំបៅកូនដោយទឹកដោះម្តាយសុទ្ធ ជួយម្តាយដាក់ទីតាំងបីបំបៅ និងបៅផ្អឹបជាប់នឹងដោះ ។ |

# ២.ពេលវេលានៃការមកពិនិត្យនិងជំហាននៃការថែទាំនិមួយៗ(ត)

| សេវាកម្ម | ពេលវេលា | កញ្ចប់សេវាដែលត្រូវផ្តល់ |
|---|---|---|
| ពិនិត្យក្រោយសម្រាលលើកទី១ | ថ្ងៃទី៧ក្រោយសម្រាល | • ផ្តល់ប្រឹក្សា/អប់រំអំពី អនាម័យខ្លួនប្រាណ ការលាងដៃមុនពេលហូបអាហារ/បំបៅកូន/ប៉ះពាល់កូន អាហារូបត្ថម្ភម្តាយ ការបំបៅកូនដោយទឹកដោះម្តាយ ការថែទាំផ្ចិត សញ្ញាគ្រោះថ្នាក់ក្រោយពេលសម្រាល ការពន្យារកំណើត<br>• ធ្វើការណាត់ជួបសម្រាប់ការពិនិត្យក្រោយសម្រាលលើកទី២ និងរំលឹកម្តាយឱ្យយកមកជាមួយនូវ សៀវភៅសុខភាពមាតា ប័ណ្ណសមធម៌ ឬ ប័ណ្ណអាទិភាព ប័ណ្ណរីង អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណសំគាល់ផ្សេងៗ<br>• កត់ត្រាព័ត៌មាននិងសេវាផ្សេងៗដែលបានផ្តល់ទៅក្នុងបញ្ជីកត់ត្រា និងសៀវភៅសុខភាពមាតា |

# ២.ពេលវេលានៃការមកពិនិត្យនិងជំហាននៃការថែទាំនិមួយៗ(ត)

| សេវាកម្ម | ពេលវេលា | កញ្ចប់សេវាដែលត្រូវផ្តល់ |
|---|---|---|
| ពិនិត្យក្រោយសម្រាលលើកទី២ | ថ្ងៃទី១៤ក្រោយសម្រាល | • យកសញ្ញាជីវិត (សម្ពាធឈាម ជីពចរ កម្តៅ ចង្វាក់ដង្ហើម)<br>• វាយតម្លៃភាពស្លេកស្លាំងឡើងវិញ/ការលេបថ្នាំជាតិដែក<br>• ប្រសិនបើស្ត្រីមិនបានមកទទួលការពិនិត្យក្រោយសម្រាលលើកទី១ ត្រូវបញ្ជូនម្តាយទៅចុះឈ្មោះនៅសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART site)ដើម្បីទទួលបានឱសថប្រឆាំងមេរោគអេដស៍(ក្នុងករណីគាត់មិនទាន់បានទទួលការព្យាបាលសោះ) |

# ២.ពេលវេលានៃការមកពិនិត្យនិងជំហាននៃការថែទាំនីមួយៗ(ត)

| សេវាកម្ម | ពេលវេលា | កញ្ចប់សេវាដែលត្រូវផ្តល់ |
|---|---|---|
| ពិនិត្យ ក្រោយ សម្រាល លើកទី២ | ថ្ងៃទី១៤ក្រោយ សម្រាល | • ផ្តល់ប្រឹក្សា/អប់រំអំពី អនាម័យខ្លួនប្រាណ ការលាងដៃមុនពេលហូប អាហារ/បំបៅកូន/ប៉ះពាល់កូន អាហារូបត្ថម្ភម្តាយ ការបំបៅកូនដោយ ទឹកដោះម្តាយ សញ្ញាគ្រោះថ្នាក់ក្រោយពេលសម្រាលទាំងម្តាយ/កូន ការពន្យារកំណើត<br>• ធ្វើការណាត់ជួបសម្រាប់ការពិនិត្យក្រោយសម្រាលលើកទី៣ និងរំលឹក ម្តាយឱ្យយកមកជាមួយនូវ សៀវភៅសុខភាពមាតា ប័ណ្ណសុខភាព ប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព ប័ណ្ណរីង អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណ សំគាល់ផ្សេងៗ<br>• កត់ត្រាព័ត៌មាននិងសេវាផ្សេងៗដែលបានផ្តល់ទៅក្នុងបញ្ជីកត់ត្រា និង សៀវភៅសុខភាពមាតា |

# ២.ពេលវេលានៃការមកពិនិត្យនិងជំហាននៃការថែទាំនីមួយៗ(ត)

| សេវាកម្ម | ពេលវេលា | កញ្ចប់សេវាដែលត្រូវផ្ដល់ |
|---|---|---|
| ពិនិត្យក្រោយសម្រាលលើកទី៣ | កូនមានអាយុ១ខែកន្លះ | • យកសញ្ញាជីវិត (សម្ពាធឈាម ជីពចរ កម្ដៅ ចង្វាក់ដង្ហើម)<br>• វាយតម្លៃភាពស្លេកស្លាំងឡើងវិញ/ការលេបថ្នាំជាតិដែក<br>• ប្រសិនបើស្ត្រីមិនបានមកទទួលការពិនិត្យក្រោយសម្រាលលើកទី២ ត្រូវបញ្ជូនម្ដាយទៅចុះឈ្មោះនៅសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART site)ដើម្បីទទួលបានឱសថប្រឆាំងមេរោគអេដស៍(ក្នុងករណីគាត់មិនទាន់បានទទួលការព្យាបាលសោះ) |

# ២.ពេលវេលានៃការមកពិនិត្យនិងជំហាននៃការថែទាំនិមួយៗ(ត)

| សេវាកម្ម | ពេលវេលា | កញ្ចប់សេវាដែលត្រូវផ្តល់ |
|---|---|---|
| ពិនិត្យក្រោយសម្រាលលើកទី៣ | កូនមានអាយុ១ខែកន្លះ | • ផ្តល់ប្រឹក្សា/អប់រំអំពី អនាម័យខ្លួនប្រាណ ការលាងដៃមុនពេលហូបអាហារ/បំបៅកូន/ប៉ះពាល់កូន អាហារូបត្ថម្ភម្តាយ(គ្មានការតមអាហារ គ្មានការប្រើស្រាថ្នាំ) ការបំបៅកូនដោយទឹកដោះម្តាយ សញ្ញាគ្រោះថ្នាក់ក្រោយពេលសម្រាល<br>• ផ្តល់ការពិគ្រោះពិភាក្សា និងផ្តល់មធ្យោបាយពន្យារកំណើតទំនើបសមស្រប និងតាមតម្រូវការ<br>• កត់ត្រាព័ត៌មាននិងសេវាផ្សេងៗដែលបានផ្តល់ទៅក្នុងបញ្ជីកត់ត្រា សៀវភៅសុខភាពមាតា |

# ៣.លទ្ធផលនៃការសិក្សា

យោងតាមរបាយការណ៍បានធ្វើការសិក្សាលើស្ត្រីមកសម្រាលកូននៅមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក រយៈពេល៥ខែគិតពីថ្ងៃទី១ខែមករា ដល់ថ្ងៃទី៣១ខែឧសភាឆ្នាំ២០២៤៖

- សម្រាលសរុប= 3583
  - សម្រាលដោយវះកាត់= 1646
  - សម្រាលដោយបូម= 72
  - សម្រាលធម្មតា= 1473
  - សម្រាលកូនបញ្ច្រាស= 48
  - សម្រាលកូនភ្លោះ= 25
  - សម្រាលមិនគ្រប់ខែ= 318

❖ កូនកើតរស់=3525 កូនស្លាប់=94

# ៣.១.ស្ត្រីដែលបានមកពិនិត្យក្រោយសម្រាលនៅមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

| ដំណាក់កាលពិនិត្យ | ចំនួនស្ត្រី | ភាគរយ |
|---|---|---|
| ពិនិត្យលើកទី១ | 1451 | |
| ពិនិត្យលើកទី២ | 1028 | |
| ពិនិត្យលើកទី៣ | 512 | |
| សរុប | 2991 | 80% នៃសម្រាលសរុប3583នាក់ |

ក្នុងនោះមានស្ត្រីសម្រាលនៅមណ្ឌល និងមន្ទីរពេទ្យផ្សេងៗចំនួន116 នាក់

# ៣.២.អាសយដ្ឋានរបស់ស្ត្រីដែលមកពិនិត្យ

- ភ្នំពេញ= 923
- ខេត្ត= 2068






# ៣.៣.មធ្យោបាយមកពិនិត្យ

- យានជំនិះផ្ទាល់ខ្លួន= 1986
- តាក់ស៊ី/ម៉ូតូកង់បី= 1005



# ៣.៤.ស្ត្រីមកពិនិត្យតាមរយៈ

- ឆ្មបទូរស័ព្ទអញ្ជើញមកពិនិត្យ= 2844
- មកពិនិត្យដោយខ្លួនឯង=147



# ៣.៥.ស្ត្រីមានប្រើប័ណ្ណសុខភាព

- ប.ស.ស = 1709
- សមធម៌ =357
- បង់ប្រាក់ =911
- អនុគ្រោះ =14



# ៣.៦.បញ្ហាដែលបានរកឃើញពេលស្ត្រីមកពិនិត្យ

| បញ្ហា | មូលហេតុ | អន្តរាគមន៍ | លទ្ធផល |
|---|---|---|---|
| ក្តៅខ្លួន>38អង្សា=10នាក់ | -២ នាក់សល់កំទេចសុក<br>-៦នាក់ក្លាយរោគថ្នេរវះកាត់<br>-២ ប៉េរីណេក្លាយរោគ | សម្រាកពេទ្យ | ជាសះស្បើយ |
| ថ្នេរប៉េរីណេ =09 នាក់ | មិនជាប់ | ថៃទាំនៅផ្ទះនិងណាត់ជួបជាបន្ត | ជាសះស្បើយ |
| សម្ពាធឈាមឡើង 140/100 =06នាក់ | មានប្រវត្តិក្រឡាភ្លើងមុនសម្រាល | ណាត់ជួបជាបន្តបន្ទាប់ | ធូរស្បើយ/តាមដាន |

# ៣.៧.មតិយោបល់និងសំណូមពររបស់ស្ត្រី

- សប្បាយចិត្តឆ្ងបរាក់ទាក់បានល្អ=2721នាក់/2991
- មិនសូវសប្បាយចិត្ត=270នាក់/2991 ( ពិបាកធ្វើដំណើរឆ្ងាយអស់ថវិកាច្រើន )
- ការពិនិត្យមានផលល្អខ្លាំង=2480នាក់/2991
- ខ្ញុំនឹងចែករំលែកដល់ស្ត្រីផ្សេងៗទៀតអោយមកពិនិត្យ=227នាក់/2991
- ៥០ភាគរយនៃស្ត្រីមកពីខេត្ត( 2068 )សុំពិនិត្យលើកក្រោយធ្វើនៅមណ្ឌលឬមន្ទីរពេទ្យដែលនៅជិតផ្ទះ ព្រោះចំណាយលុយអស់ច្រើននិងចំណាយពេលយូរ

# ៤.សេចក្តីសន្និដ្ឋាន

យោងតាមករណីសិក្សាដែលបានរកឃើញ បានអោយដឹងថា ស្ត្រីក្រោយសម្រាលកូនមិនអោយលើស៤២ថ្ងៃត្រូវមកពិនិត្យក្រោយសម្រាលពងដោយចាំបាច់ ព្រោះបញ្ហាដែលបានរកឃើញដូចជា**ក្តៅខ្លួន ផ្ទេរប៉េរីណេមិនជាប់ និង សម្ពាធឈាមឡើងចំនួន** សុទ្ធតែជាកត្តាគ្រោះថ្នាក់អាចដល់ស្លាប់បានប្រសិនបើស្ត្រីមិនបានទទួលការព្យាបាលបានត្រឹមត្រូវ។

ម៉្យាងវិញទៀតស្ត្រីមានអារម្មណ៍កក់ក្តៅនិងមានទំនុកចិត្តនិងពេញចិត្តឆ្លបនូវការយកចិត្តទុកដាក់ពីសុខភាពរបស់គាត់ដោយមានការអញ្ជើញតាមទូរស័ព្ទឲ្យគាត់អោយមកពិនិត្យសុខភាព។

ចំពោះស្ត្រីដែលសម្រាលឆ្ងាយពីផ្ទះឃើញថា៥០ភាគរយចង់ពិនិត្យក្រោយសម្រាលនៅជិតផ្ទះគាត់វិញ។

# ៥.អនុសាសន៍

យោងតាមសេចក្ដីសន្និដ្ឋានឆ្នបដែលផ្ដល់សេវានៅមូលដ្ឋានសុខាភិបាលត្រូវ៖

- ដឹងពីពេលវេលាដែលស្ត្រីត្រូវមកពិនិត្យក្រោយសម្រាលជាទៀងទាត់
- សួរពីអារម្មណ៍របស់ស្ត្រីដើម្បីបំពេញនូវតម្រូវការរបស់គាត់តាមដែលអាចធ្វើបាន
- ប្រាប់ស្ត្រីអោយទៅពិនិត្យក្រោយសម្រាលនៅមណ្ឌលសុខភាពឬមន្ទីរពេទ្យដែលនៅជិតផ្ទះគាត់បាន
- ពិនិត្យស្ត្រីយ៉ាងយកចិត្តទុកដាក់ទើបអាចរកសញ្ញាគ្រោះថ្នាក់ឃើញដើម្បីជួយអន្តរាគមន៍ទាន់ពេល
- ណាត់ឬបញ្ជាក់ពីថ្ងៃខែដែលត្រូវមកពិនិត្យក្រោយសម្រាលមុនពេលស្ត្រីចេញពីមន្ទីរពេទ្យ
- ទូរស័ព្ទប្រាប់ទៅស្ត្រីរំលឹកពីថ្ងៃដែលត្រូវមកពិនិត្យ

# ឯកសារយោង

-ពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់២០២០

-កញ្ចប់សេវាពេលមានផ្ទៃពោះ សម្រាល និងក្រោយសម្រាល( ១០០០ថ្ងៃ )

- របាយការណ៍ NMCHC ថ្ងៃទី1ខែ1-ថ្ងៃទី31ខែ5/2024

# សូមអរគុណ

